

## ៤) ការស្តុកទុក

យើងអាចស្តុកស្ពៃក្តោបដោយធ្វើការ រុំក្រដាសកាសែត ហើយយកវាទៅដាក់ ក្នុងធុងត្រដាក់/ពាងធ្វើពីដីគ្របក្រណាត់សើម ហើយ ប្រោះទឹក ១ ថ្ងៃ ២ ដង (ព្រឹក-ល្ងាច) លើក្រណាត់នោះ នៅពេលវាស្ងួត។ ជាលទ្ធផលគឺអាចរក្សាទុកបានយូររហូត ដល់ ១៦ ថ្ងៃ ដោយពុំមានស្រកទំងន់ឡើយ។





រូបភាពមុនពេលរក្សាទុក



រូបភាពក្រោយពេលរក្សាទុកបាន ១៦ ថ្ងៃ

---

**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

រុំធ វណ្ណឌី, ឌុល វណ្ណឌី និង ជាម គីមលី

# វិធីសាស្ត្រគ្រប់គ្រង
# ស្ពៃក្តោប
## ក្រោយពេលប្រមូលផល



មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Centre d'Etude et de Développement Agricole Cambodgien

វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction

ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណាយ
Funded by McKnight Foundation

## ១) ការប្រមូលផល

- ជាទូទៅ យើងប្រមូលផលស្ពៃក្តោបដោយសំគាល់ទៅលើអាយុរបស់វា គឺចាប់ពី ៣ ទៅ ៣ ខែកន្លះ បន្ទាប់ពីដាក់គ្រាប់ដល់ដី
- បន្ទាប់ពីនេះ គឺការពិនិត្យទៅលើលក្ខណៈក្តោបរបស់ស្ពៃ ដូចជាយកដៃច្របាច់ទៅលើវា បើរឹងល្អ មានន័យថាស្ពៃពេញវ័យអាចប្រមូលផលបាន ឬសំគាល់ទៅលើចុងស្លឹកស្រទាប់ក្រៅរបស់វាមូរ
- ពេលប្រមូលផល គឺធ្វើឡើងនៅពេលល្ងាចត្រជាក់ល្អពីម៉ោង ៣-៤ ដើម្បីឱ្យទឹកសន្សើមស្រស់ល្អ
- ការប្រមូលផលត្រូវយកកូនកាំបិតចុងស្រួចដែលមុតល្អកាត់វាដោយទាញក្តោបរាងផ្អៀកបន្តិច រួចទើបកាត់





- ការប្រមូលផលត្រូវធ្វើឡើងនៅពេលមានអាកាសធាតុស្ងួតល្អ។ កាលណាយើងប្រមូលផលនៅពេលភ្លៀង ឬបន្ទាប់ពីភ្លៀងភ្លាមៗ នោះធ្វើឱ្យមេរោគងាយបង្កជំងឺឱ្យស្ពៃក្តោបឆាប់រលួយ។

## ២) ការតំរឹម និងសំអាត

- ក្រោយពីកាត់រួច យើងពុំចាំបាច់បកស្រទាប់ក្រៅចេញទេ គឺគ្រាន់តែតំរឹមឱ្យស្អាត ហើយលាបកំបោរ ភ្លាមៗ ឬសាច់ជូរនៅមុខកាត់ ដើម្បីការពារការចេញ ជ័រច្រើន ឬឆ្លងជំងឺផ្សេងៗ។ បន្ទាប់មក យកវាទៅដាក់ ក្នុងម្លប់ថ្មមៗហើយមិនដាក់គរលើគ្នាទេ ជៀសវាងកុំឱ្យជាំ
- ការសំអាត គឺយើងគ្រាន់តែកាត់សំបកបន្តិចបន្តួចបានហើយ រួចប្រញាប់យកវាទៅដាក់នៅកន្លែងម្លប់ត្រជាក់ ដើម្បីកុំឱ្យហួតជាតិទឹក ស្វិតស្រពោនបាត់បង់ទំងន់។





## ៣) ការវេចខ្ចប់ និងដឹកជញ្ជូន

- ដើម្បីឱ្យការវេចខ្ចប់ និងដឹកជញ្ជូនបានល្អ មិនបាត់បង់ យើងអាចប្រើចំបើង ក្រដាស បាវ ស្លឹកចេក ឬស្លឹកឈូកសំរាប់ធ្វើជាទ្រនាប់ ដើម្បីកាត់បន្ថយការប៉ះទង្គិច
- ឯការដឹកជញ្ជូន គួរដាក់តាមថ្នាក់ៗ ជៀសវាងការដាក់គរលើគ្នា
- ប្រសិនបើអាចធ្វើបាន យើងអាចយកក្រដាសកាសែតមកហុំលើក្តោបនិមួយៗ តែម្តង ទើបដាក់បញ្ចូលក្នុងកញ្ជេ
- ជៀសវាងការបកផាងស្រទាប់ក្រៅរបស់វាមុនពេលដាក់លក់លើស្តង់
- ពេលដឹកជញ្ជូន ត្រូវរក្សាឱ្យមានគំរបជានិច្ចដើម្បីការ-ពារកំដៅ និងធូលី។

